ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បញ្ញត្តិករទូរគមនាគមន៍កម្ពុជា

លេខ : ០៥៣២ ប.ក.ទ.ក./ល

# សេចក្តីជូនដំណឹង

លេខាធិការដ្ឋាននៃ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា មានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាប្រតិបត្តិករ និងអ្នកទទួលប្រើប្រាស់សេវាទូរគមនាគមន៍ ទាំងអស់ជ្រាបថា៖ ដើម្បីបង្កលក្ខណៈងាយស្រួល និងឆាប់រហ័ស សន្សំសំចៃពេលវេលាជូនប្រតិបត្តិករ និងអ្នកទទួលប្រើប្រាស់សេវាទូរគមនាគមន៍ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា បានពិនិត្យ និងកែសម្រួលនីតិវិធីនៃការទូទាត់វិក្កយបត្រ និងកម្រៃផ្សេងៗ មកបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អាចធ្វើការទូទាត់តាមនីតិវិធីដូចខាងក្រោម៖

១- អាចធ្វើការទូទាត់ជាសាច់ប្រាក់ ឬមូលប្បទានប័ត្រ ឬបណ្ណឥណទាន/ឥណពន្ធ (VISA CashCard, ATM Debit) នៅការិយាល័យបេឡាធិការ នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ដែលមានអាសយដ្ឋានកាច់ជ្រុងវិថីលេខ១៣ និង១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬ

២-អាចធ្វើការទូទាត់តាមការដាក់ប្រាក់ ឬបង្វែរចូលគណនីរបស់ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា នៅធនាគារពាណិជ្ជកម្មក្រៅប្រទេស FTB សម្រាប់ប្រាក់ដុល្លារអាមេរិកគណនីលេខ -USD: A/C No. 010300640009212 និងសម្រាប់ប្រាក់រៀលគណនីលេខ -KHR: A/C No. 010012900000139 ឬ

៣- អាចធ្វើការទូទាត់តាមប្រព័ន្ធ Internet Banking របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស FTB ដែលមានគេហទំព័រ www.ftbbank.com ( ករណីនេះអតិថិជនត្រូវមានគណនីជាមួយធនាគារពាណិជ្ជកម្មក្រៅប្រទេស FTB និងចុះឈ្មោះក្នុងប្រព័ន្ធ Internet Banking ) ឬ

៤- អាចធ្វើការទូទាត់តាមរយៈគ្រប់សាខាធនាគារពាណិជ្ជកម្មក្រៅប្រទេស FTB ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយយកភ្ជាប់ជាមួយនូវវិក្កយបត្រ ឬឯកសារពាក់ព័ន្ធដែលត្រូវធ្វើការទូទាត់។

ទទួលបានសេចក្តីជូនដំណឹងខាងលើ សូមឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥

**ប្រធានលេខាធិការដ្ឋាន**

TELECOMMUNICATION REGULATOR OF CAMBODIA
T.R.C.

**សុខ ឡៃ**